# របាយការណ៍ប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទ
# ខេត្តឧត្តរមានជ័យ

## ១. សេចក្ដីផ្ដើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើង ប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរ ចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- លោកប្រធានមន្ទីរ បានចូលរួមពិធីប្រកាសតែងតាំង ប្រគល់ភារកិច្ច និងផ្លាស់ប្ដូរភារកិច្ចមន្ត្រីរាជការ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ និងឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ។ លោកប្រធានមន្ទីរ បានចូលរួមពិធីសាងសង់ផ្ទះជូនដល់គ្រួសារចាស់ជរាទីទ័លក្រ នៅភូមិអូរត្រាច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ បានប្រជុំស្ដីពីការពិនិត្យឡើងវិញការអនុវត្តកម្មវិធីឆ្នាំ២០១៤ និងការលើកផែនការឆ្នាំ២០១៥ នៅខេត្តបាត់ដំបង បានចូលរួមពិធីបុណ្យបូជាព្រះសព ព្រះគ្រូ ឧត្តរវ៉ា សី យង់ តិក ក្រោមអធិបតីភាពសម្ដេចព្រះសង្ឃរាជាធិបតី **ទេព្យ វង្ស** សម្ដេចសង្ឃរាជា នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តប្រាសាទសំរោងរាជា។ ប្រធានមន្ទីរ បានចូលរួមប្រជុំពាក់ព័ន្ធអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចស្ដីពីការណែនាំឱ្យកែលម្អចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរអភិវឌ្ឍន៍ជនបទ នៅទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ និងបានប្រជុំត្រៀមផែនការការពារព្រះរាជដំណើររបស់ព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្រោមអធិបតីភាព **ឯកឧត្តម ទូច ណារុថ** អគ្គស្នងការរងនគរបាលជាតិ នៅសាលប្រជុំតូចសាលាខេត្តឧត្តរមានជ័យ។
- លោកប្រធានមន្ទីរ ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យចូលរួមក្នុងកម្មវិធីសន្និបាតបូកសរុប

លទ្ធផលការងារឆ្នាំ២០១៤ និងលើកទិសដៅការងារ ឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសីទចកតុមុខ រាជធានីភ្នំពេញ។ ជាមួយគ្នានេះ មន្ត្រីមន្ទីរបានចូលរួមពិធីប្រកាសតែងតាំងនាយករដ្ឋបាលសាលាខេត្ត នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ និងបានចូលរួមប្រជុំសាមញ្ញលើកទី១០ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តនៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ ។

- លោកប្រធានមន្ទីរ និងមន្ត្រីការិយាល័យ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកា កម្មវិធីនៅថ្នាក់រាជធានីខេត្ត នៅសណ្ឋាគារព្រះច័ន្ទ ខេត្តបន្ទាយមានជ័យ និងបានចូលរួមសិក្ខាសាលាបូកសរុបការងារបញ្ជី សារពើព័ន្ធផ្លូវប្រចាំឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំពេញ ។ ពិធីចែកប័ណ្ណកម្មសិទ្ធិ និងចែកអំណោយជូនប្រជាពលរដ្ឋក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅច្រកជប់គគី ស្រុកបន្ទាយអំពិល ។
- ថ្នាក់ដឹកនាំមន្ទីរបានចូលរួមពិធីចែកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅស្រុកត្រពាំងប្រាសាទក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅស្រុកត្រពាំងប្រាសាទ និងបានចូលរួមប្រជុំដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធ និងការស្ថាបនាផ្លូវច្រកជប់គគីរ ក្រោមអធិបតីភាព ឯកឧត្តម **វ៉ាត ប៉ារ៉ានីន** អភិបាលរងខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ។ ចូលរួមពិធីដង្ហែរព្រះសពព្រះគ្រូឧត្តរវាសី យង់ តិក អតីតព្រះមេគុណខេត្តឧត្តរមានជ័យ នៅវង្វង់មូល ព្រះបាទជ័យវរ្ម័នទី៧ ដង្ហែរមកកាន់វត្តប្រាសាទរាជា បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់តម្រង់ ទិសថ្នាក់ជាតិស្តីពីក្របខ័ណ្ឌលទ្ធផលនៃផែនការសកម្មភាពជាតិសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០១៨ នៅសណ្ឋាគារ Le Royal រាជធានីភ្នំពេញ និងបានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០១៥ របស់រដ្ឋបាលខេត្តខេត្តឧត្តរមានជ័យ។ បានចូលរួមប្រជុំពិភាក្សាបង្កើនមេត្រីភាព ដើម្បីជំរុញក្នុងការបើកច្រកទ្វារព្រំដែនអន្តរជាតិជប់គគី សាយតាគួ ជាអចិន្ត្រៃយ៍ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** នៅទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិជប់គគី។ បានចូលរួមពិធីទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី១៧ ឆ្នាំ២០១៥ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ បានចូលរួមពិធីសម្ពោធពិពណ៌អបអរសាទរ ពិធីបុណ្យដាលានបញ្ចប់រដូវច្រូតកាត់លើកទី០១ ឆ្នាំ២០១៥ ក្រោមអធិបតីភាពភាព ឯកឧត្តម **ស ថាវី** នៅសណ្ឋាគារ និងកាស៊ីណូ សាង៉ាំ វីសត ។ បានចូលរួមពិធីបើក និងបិទការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្ត ឆ្នាំសិក្សា២០១៤-២០១៥ នៅពហុកីឡាដ្ឋានខេត្តឧត្តរមានជ័យ បានចូលរួមពិធីប្រកាសចូលកាន់តំណែង អភិបាលស្រុក អន្លង់វែង នៅសាលាស្រុកអន្លង់វែង បានចូលរួមពិធីសម្ពោធផ្លូវក្នុងភូមិសាស្ត្រស្រុកត្រពាំងប្រាសាទ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** នៅទីស្នាក់ការក្រុមហ៊ុន OddorMeanchey Sugar (ODMS) co,Ltd ភូមិឈើទាលជ្រុំ ឃុំអូរស្វាយ។

- ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យបានចូលរួមកិច្ចប្រជុំពិភាក្សាអំពីការតែងតាំងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ និងការត្រៀមអនុវត្តរបៀបនៃការចុះលេខលិខិតថ្មីសម្រាប់ឆ្នាំ២០១៥ នៅទីស្ដីការក្រសួងអភិវឌ្ឍន៍ជនបទ។
- មន្ត្រីការិយាល័យបានចូលរួមសិក្ខាសាលាសមាហរណកម្មផែនការ ឃុំសង្កាត់ ថ្នាក់ក្រុងស្រុកចំនួន ០២លើក នៅស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល។ ពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ វត្តបុរីប្រាសាទជ័យ នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ និងប្រជុំស្ដីពីការឆ្លើយតបវិធានការវិន័យរដ្ឋបាល និងកែកំហុសឆ្គងនៃការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ឆ្នាំ២០១៣ ក្រោមអធិបតីភាពឯកឧត្ដម **ស៊ុី ប្រាសិទ្ធ** អភិបាលរងខេត្ត នៅសាលាខេត្តឧត្តរមានជ័យ។ សិក្ខាសាលាបូក សរុបសមិទ្ធិផលការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ឆ្នាំ២០១៤ និងកិច្ចសហប្រតិបត្តិការ ឆ្នាំ២០១៥ នៅសណ្ឋាគារ ភ្នំពេញ ។ ចូលរួមកម្មវិធីផ្សព្វផ្សាយសារាចរណែនាំលេខ ០០១សហវ ស្ដីពីការអនុវត្តច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការ គ្រប់គ្រង ឆ្នាំ២០១៥ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។ ប្រជុំសាមញ្ញលើកទី៨ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី២ ក្រោមអធិបតីភាពឯកឧត្តម **យិម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តឧត្តរមានជ័យ។ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្ដីពីការរៀបចំគម្រោងរាជធានី ខេត្ត ក្រោមអធិបតីភាពឯកឧត្តម **ស៊ុី ប្រាសិទ្ធិ** អភិបាលរងខេត្ត នៅសាលាខេត្តឧត្តរមានជ័យ។ ចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីជំនាញគ្រប់គ្រងស្ថាប័នប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងទំនាស់ និងដំណោះស្រាយ និងការគ្រប់គ្រងប្រសិទ្ធភាពការងារ នៅសណ្ឋាគារ ឈឿន ប្រាក់កប ខេត្តឧត្តរមានជ័យ។ ចូលរួមសិក្ខាសាលា ស្ដីពីកាបង្ហាញលទ្ធផលវាយតម្លៃបញ្ចប់គម្រោង នៅសណ្ឋាគារ Green palace រាជធានីភ្នំពេញ។ ប្រជុំដោះស្រាយការរៀបចំសណ្ដាប់ធ្នាប់ និងការកែលម្អសោភ័ណ្ឌភាពច្រកទ្វារអន្តរជាតិជាំ និងការផ្លាស់ប្ដូរទីតាំងធ្វើអាជីវកម្មរបស់អាជីវករ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្ត ឧត្តរមានជ័យ នៅផ្សារផលសាម៉ន ស្រុកអន្លង់វែង ។ ចូលរួមព្រះរាជពិធីប្រោសប្រទានព្រះរាជអំណោយរបស់ព្រះ ករុណាជាម្ចាស់ជីវិតតម្កល់លើត្បូង **ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅភូមិគោល ឃុំក្រសាំង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ ប្រជុំសាមញ្ញលើកទី៩ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី២ ក្រោមអធិបតីភាពឯកឧត្តម **ឡៅ ឆន** ប្រធានក្រុមប្រឹក្សាខេត្តស្ដីទី នៅសាលប្រជុំធំសាលាខេត្ត។ ប្រជុំផ្សព្វផ្សាយគណៈកម្មការរបស់កម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចតំបន់ក្រវ៉ាត់បៃតងប្រចាំខេត្តឧត្តរមានជ័យ នៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ។ ពិធីសម្ពោធឱ្យដំណើរការកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចតំបន់ក្រវ៉ាត់បៃតងប្រចាំខេត្តឧត្តរមានជ័យ នៅភោជនីដ្ឋានផ្កាយព្រឹក ខេត្តឧត្តរមានជ័យ។ ចូលរួមពិធីសំណេះសំណាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **សេរី កុសល** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសក

កម្មពិសេស និងជាអនុប្រធានទី២ អាជ្ញាធរមីន នៅសាលប្រជុំតូចសាលាខេត្តឧត្តរមានជ័យ។ ប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីព្រៃឈើ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចូលរួមពិធីប្រកាសតែងតាំងមុខតំណែងប្រធានមន្ទីរសុខាភិបាល នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ ។ ចូលរួមសន្និសីទជាតិអាហារូបត្ថម្ភ នៅសណ្ឋាគារអាំងទ័រកង់ទី ណង់កាល់ រាជធានីភ្នំពេញ ។ ប្រជុំពិភាក្សាលើគម្រោងស្តារឡើងវិញផ្លូវជាតិលេខ៥៨ (ប៉ោយប៉ែត ក្រុងសំរោង) នៅ សាលប្រជុំលេខ ១២សាលាខេត្តឧត្តរមានជ័យ។ ចូលរួមប្រារព្ធខួបលើកទី ១០៤ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** និងលោកជំទាវ នៅសាលប្រជុំធំសាលាខេត្តឧត្តរមានជ័យ។ ប្រជុំ Pro TWGH និងគណកម្មការហិរញ្ញប្បទាននៅមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- សិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបលទ្ធផលការងារ ស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំឆ្នាំ២០១៤
- ចុះស្រង់ទិន្នន័យផ្លូវ នៅស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងស្រុកអន្លង់វែង និង
- ចុះក្រាលក្រួសក្រហមនៅស្រុកអន្លង់វែង ប្រវែងសរុប ៣ ៦៣២ ម៉ែត្រ នៅស្រុកចុងកាល់ ប្រវែងសរុប ៤០០ ម៉ែត្រ នៅស្រុកបន្ទាយអំពិល ប្រវែងសរុប ២ ៣៩៥ ម៉ែត្រ និងនៅក្រុងសំរោង ប្រវែងសរុប ២ ៩៨០ ម៉ែត្រ របស់គម្រោងឧត្តម្ភស្បៀងបន្ទាន់។

### ៣.២ ការងារថែទាំសុខភាពជនបទ

- រួមប្រជុំពិគ្រោះយោបល់ ស្តីពីការលើកកម្ពស់អនាម័យជនបទ តាមរយៈវិទ្យុខេត្ត នៅសណ្ឋាគារអាស៊ីខេត្តកំពង់ឆ្នាំង។ កិច្ចប្រជុំនេះ រៀបចំដោយនាយកដ្ឋានថែទាំសុខភាពជនបទ និងមានអ្នកចូលរួមសរុបចំនួន ២៧ នាក់ ស្ត្រី ០៨ នាក់
- ចុះសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ មានភូមិគោលដៅសរុប ៤៣ ភូមិ ០៥ ឃុំ និង ០២ ស្រុក និងមានអ្នកចូលរួមសរុបចំនួន ១១៩ នាក់ ស្ត្រី ១៨ នាក់
- រៀបចំកម្មវិធីអប់រំលើកកម្ពស់អនាម័យតាមរយៈវិទ្យុ (កម្មវិធីសំនួរ-ចម្លើយ និងកិច្ចពិភាក្សាតុមូល) សម្របសម្រួលដោយស្ថានីយ៍វិទ្យុ គីរីដងរែក FM90.25 MHz
- ចុះត្រួតពិនិត្យ និងវាយតម្លៃ ស្តីពីការប្រតិបត្តិអនាម័យរបស់សហគមន៍ ចំនួន ០២ លើក នៅភូមិគោលដៅ ៤៣ ភូមិ ០៥ ឃុំ និង ០២ ស្រុក និងមានអ្នកចូលរួមសរុបចំនួន ២ ៥៥៤ នាក់ ស្ត្រី ១ ៧០៧ នាក់ និងចុះត្រួតពិនិត្យការងារសាងសង់បង្គន់អនាម័យនៅតាមភូមិគោលដៅចំនួន ១២ ភូមិ ស្ថិតនៅឃុំចុងកាល់ ឃុំពង្រ ស្រុកចុងកាល់ និងឃុំបេង ស្រុកបន្ទាយអំពិល (គម្រោងរបស់

រាជរដ្ឋាភិបាលកម្ពុជា)

- ចូលរួមកិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យឡើងវិញការអនុវត្តកម្មវិធីឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥ របស់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី ម៉េង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារ ខេមរា ខេត្តបាត់ដំបង និងមានអ្នកចូលរួមសរុបចំនួន ៤៥ នាក់ ស្ត្រី ០៧ នាក់
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់ ឡើងវិញទៅលើភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ១០០ %ចំនួន ០១ ភូមិ ស្ថិតក្នុងភូមិគោកធ្នង់ ឃុំក្រសាំង ស្រុកចុងកាល់ មានចូលរួមសរុបចំនួន ១០៦ នាក់ ស្ត្រីចំនួន ៧៣ នាក់
- ចូលរួមសិក្ខាសាលាមួយស្តីពី សិក្ខាសាលាបញ្ចប់កម្មវិធីផ្នែក សុខភាពអាហាររូបត្ថម្ភ បំនិនជីវិត និងអនាម័យ អនុវត្តតាមរយៈអង្គការ Plan និងអង្គការដៃគូរ ក្រោមអធិបតីភាពឯកឧត្តម **វង្ស សណ្តាប់** អនុរដ្ឋលេខាធិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជានាយក គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ -ហិរញ្ញប្បទានបន្ថែម ( EFAP-AF )ថ្នាក់ជាតិ នៅសណ្ឋាគារខេមរាអង្គ ខេត្តសៀមរាប និង
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញទៅលើភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ១០០ %ចំនួន ០៩ ភូមិ ស្ថិតក្នុងឃុំក្រសាំង ស្រុកចុងកាល់ រួមមានភូមិ គោកស្លាន គោកសម្រេច គោកធំ គោល ឈូក ចេក្ស រលំវែង បន្ទាត់បោះ និងភូមិខ្នា។ សកម្មភាពនេះមានក្រុមការងារចុះត្រួតពិនិត្យ និងវាយតម្លៃ ដែលមានសមាសភាពមកពី PDRD អាជ្ញាធរឃុំ ថ្នាក់ភូមិ និងប្រជាពលរដ្ឋចូលរួមសរុបចំនួន ៤០៥ នាក់ ស្ត្រីចំនួន ២៦៣នាក់។

### ៣.៣ ការងារផ្គត់ផ្គង់ទឹកស្អាត

- ចូលរួមប្រជុំ ស្តីពីការពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- ចូលរួមសិក្ខាសាលា ស្តីពីការបង្ហាញលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រ ២០១៣-២០១៦ របស់អង្គារប៉ាក់ដេក (PADEK) នៅសណ្ឋាគារអ៊ិមភើរៀ
- ចូលរួមសិក្ខាសាលាប្រចាំឆ្នាំ ស្តីពីកម្មវិធីផែនការសុវត្ថិភាពទឹកផឹកជនបទ នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា- ជប៉ុន (CJCC) រាជធានីភ្នំពេញ
- ចូលរួមពិធីបើកសន្និបាតបូកសរុបការងារអប់រំ ប្រចាំឆ្នាំសិក្សា ២០១៣-២០១៤ និងលើកទិសដៅបន្តនៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ។
- បើកកិច្ចប្រជុំថ្នាក់ខេត្ត ស្តីពីការត្រៀមរៀបចំកសាងផែនការសកម្មភាពសម្រាប់ការងារផ្គត់ផ្គង់ទឹក និងអនាម័យជនបទខេត្ត ២០១៤-២០១៨ សម្របសម្រួលដោយលោក ប្រិច រ៉ាមី អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត

- សហការជាមួយគណៈកម្មការហិរញ្ញប្បទានមន្ទីរសុខាភិបាលខេត្ត ចុះត្រួតពិនិត្យ និងសំភាសន៍អ្នកជម្ងឺ នៅមន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង បាន ១៣ ភូមិ ០៤ ឃុំ ស្មើនឹង ៣២ នាក់ និងនៅ ស្រុកត្រពាំងប្រាសាទ បាន ០៣ ភូមិ ០២ ឃុំ ស្មើនឹង ១២ នាក់ គាំទ្រហិរញ្ញប្បទានដោយអង្គការមូលនិធិសមធម៌ (CHC) និង
- ថ្ងៃទី១៩ ខែមីនា មន្ត្រីការិយាល័យ ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យ នៅមន្ទីរអប់រំ យុវជន និងកីឡា។

**៣.៤ ការងារអភិវឌ្ឍន៍សហគមន៍**

ចុះស្រង់ព័ត៌មានភូមិ ស្ដីពីស្ថានភាពរួមក្នុងភូមិ នៅភូមិសំរោងសែនជ័យ ១ ឃុំកូនក្រៀល ក្រុងសំរោង ដែលជាលទ្ធផល នៅភូមិសំរោងសែនជ័យ ១ មានផ្ទៃដី ២៨៥ ហិចតា និងមាន ១៤៥ គ្រួសារ ស្មើនឹង ៦៨៥ នាក់ ស្រ្តី ៣២៥ នាក់។

**៣.៥ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

- ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំអំពិល ស្ដីពីប្រវត្តិផ្សារជនបទ និង
- ចុះស្រង់ទិន្នន័យផ្សារជនបទ នៅភូមិអំពិល ឃុំអំពិល ស្រុកបន្ទាយអំពិល នៅឃុំចុងកាល ស្រុកចុងកាល់។

**៣.៦ ការងារជនជាតិដើមភាគតិច**

ចុះស្រង់ទិន្នន័យជនជាតិដើមភាគតិច និងអំបូរជនជាតិនានា ក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង។

**៣.៧ ការងារការិយាល័យក្រុង -ស្រុក**

- ចូលរួមធ្វើផែនការសមាហរណកម្មថ្នាក់ស្រុកចុងកាល់
- ចូលរួមធ្វើសមាហរណកម្មផែនការថ្នាក់ស្រុក នៅសាលាស្រុកបន្ទាយអំពិល
- ចូលរួមប្រជុំវិសាមញ្ញលើកទី៧ អាណត្តិទី២ របស់ក្រុមប្រឹក្សាស្រុកបន្ទាយអំពិល
- ចូលរួមប្រជុំវិសាមញ្ញ ០២ លើក (លើកទី ៧ និងទី ៨ អាណត្តិទី ២) របស់ក្រុមប្រឹក្សាស្រុកចុងកាល់
- ចុះជួយជួសជុលអណ្ដូងស្នប់អាហ្វ្រីដេវ ០២ លើក លើកទី ០១ នៅភូមិអំពិល ឃុំពង្រ ស្រុកចុងកាល់
- ចូលរួមប្រជុំស្ដីពីការចុះកិច្ចសន្យាគម្រោងផ្លូវក្រាលគ្រួសក្រហមឆ្នាំ២០១៤ នៅភូមិសុភាព ភូមិគោកព្រិច និងភូមិឪឡោក ក្នុងឃុំអំពិល ស្រុកបន្ទាយអំពិល
- ចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម យឹម ធិន ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាស្រុកបន្ទាយអំពិល
- ចូលរួមប្រជុំប្រចាំខែ របស់គណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារ នៅសាលាស្រុកចុងកាល់
- ចូលរួមប្រជុំ ស្ដីពីការទទួលផែនការ ដើម្បីរៀបចំកន្លែងសម្រាប់ទទួលព្រះមហាក្សត្រ យាងមកចែកព្រះរាជអំណោយ នៅភូមិគោល ឃុំក្រសាំង ស្រុកចុងកាល់

- ចូលរួមប្រជុំ ជាមួយអង្គការ RCEDO នៅសាលាស្រុកចុងកាល់
- ចូលរួមក្នុងពិធីទទួលព្រះមហាក្សត្រយាងមកចែកព្រះរាជអំណោយ នៅភូមិគោល ឃុំក្រសាំង ស្រុកចុងកាល់
- ចូលរួមកិច្ចប្រជុំ គ.ក.ស.ក. ប្រចាំខែកុម្ភៈ នៅសាលាក្រុងសំរោង
- ចូលរួមសិក្ខាសាលាតម្រង់ទិស ស្តីពីកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ក្រវ៉ាត់បៃតង រៀបចំដោយអង្គការ GIZ នៅសាលាក្រុងសំរោង។

**៤. ទិសដៅការងារបន្ត**

- ចុះស្រង់ទិន្នន័យផ្លូវថ្មី និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវ នៅស្រុកត្រពាំងប្រាសាទ ស្រុកអន្លង់វែង និងស្រុកបន្ទាយអំពិល និងក្រុងសំរោង
- ចុះតាមដានបច្ចេកទេសផ្លូវក្រាលគ្រួសក្រហម របស់គម្រោងឧត្តម្ភស្បៀងបន្ទាន់
- ចុះប្រមូលទិន្នន័យខ្សែផ្លូវសាងសង់ថ្មី និងសំណង់សិល្បៈការ (សារពើភ័ណ្ឌផ្លូវ)
- ចុះត្រួតពិនិត្យការងារសាងសង់បង្គន់អនាម័យ ១២ ភូមិ ស្ថិតក្នុងឃុំចុងកាល់ ឃុំពង្រ និងឃុំបេង
- ចូលរួមរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យជនបទ ជាមួយអង្គការដៃគូរ និងស្ថាប័នពាក់ព័ន្ធ
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ៤៥ អណ្តូង និងស្រះសហគមន៍០១កន្លែង (MRD)
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ២១ អណ្តូង មានទីតាំងនៅស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិល
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ ១៣ អណ្តូង មានទីតាំងនៅក្រុងសំរោង និងស្រុកបន្ទាយអំពិល
- ជួសជុលអណ្តូងស្នប់លេខ ៦ ចំនួន ១១ អណ្តូង មានទីតាំងនៅក្រុងសំរោង
- សាងសង់ស្រះសហគមន៍ ០១ កន្លែង មានទីតាំងនៅស្រុកបន្ទាយអំពិល
- ចុះស្រង់ទិន្នន័យធនាគារស្រូវ គោ ក្នុងស្រុកចុងកាល់ និង
- រៀបចំផែនការសម្រាប់ត្រីមាសទី១ និងទី២ ឆ្នាំ២០១៥ ។